

# បេនយ៉ាមីន

## និយាយអំពីពង្សប្រវត្តិ



*បេនយ៉ាមីនមកពីទីក្រុង ប៊ុយណូហ្សែ ប្រទេសអាហ្សង់ទីន ។*

*យើងបានសួរគាត់នូវសំណួរខ្លះៗអំពីពង្សប្រវត្តិ ។*



**តើប្អូនចាប់ផ្ដើមធ្វើពង្សប្រវត្តិដោយរបៀបណា ?**

ខ្ញុំបានចាប់ផ្ដើមធ្វើពង្សប្រវត្តិ ជាមួយប៉ារបស់ខ្ញុំ ។ យើងបានធ្វើវាជាមួយគ្នារៀងរាល់ថ្ងៃអាទិត្យ ។ ប៉ារបស់ខ្ញុំបានជួយខ្ញុំរៀនពីរបៀបប្រើកម្មវិធីស្រាវជ្រាវក្រុមគ្រួសារ ។ ខ្ញុំត្រូវតែអនុវត្តហើយអនុវត្តទៀត ។ ឥឡូវខ្ញុំធ្វើពង្សប្រវត្តិជាមួយប៉ារបស់ខ្ញុំ ឬប្អូនជីដូនមួយខ្ញុំ ចាស្មីណា ។

**តើប្អូនចូលចិត្តអ្វីខ្លាំងបំផុតអំពីពង្សប្រវត្តិ ?**

ខ្ញុំចូលចិត្តរកមនុស្សថ្មីៗដើម្បីបន្ថែមទៅក្នុងមែកធាងគ្រួសាររបស់ខ្ញុំ ។ ពីដំបូង ខ្ញុំរកកំណត់ត្រាចាស់ៗ ។ បន្ទាប់មក ខ្ញុំរកឈ្មោះបុព្វការីជនរបស់ខ្ញុំ ។ ខ្ញុំរកថ្ងៃខែឆ្នាំកំណើតរបស់ពួកលោក និងកន្លែងដែលពួកលោកបានកើត ។ ខ្ញុំរកកន្លែងផ្សេងៗទៀតដែលពួកលោកបានរស់នៅផងដែរ ។



**តើប្អូនបានរៀនអ្វីខ្លះអំពីបុព្វការីជនរបស់ប្អូន ?**

ខ្ញុំបានរៀនថាខ្ញុំមានបុព្វការីជនមកពីប្រទេសអ៊ីតាលី និងប្រទេសអាល្លឺម៉ង់ ។ បុព្វការីជនរបស់ខ្ញុំមួយរូបមកពីប្រទេសអ៊ីតាលីមានឈ្មោះដូចប្អូនប្រុសខ្ញុំអ៊ីចឹង ! ឈ្មោះរបស់ប្អូនប្រុសខ្ញុំគឺ « សាន់ត្យាហ្គោ » ដែលត្រូវនឹង « ហ្គីកូម៉ូ » ជាភាសាអ៊ីតាលី ។ ខ្ញុំក៏បានរៀនដែរថា ឈ្មោះត្រកូលរបស់យើងធ្លាប់ប្រកបខុសពីនេះ ។

**តើប្អូនជួយអ្នកដទៃធ្វើពង្សប្រវត្តិដោយរបៀបណា ?**

ខ្ញុំជួយយាយរបស់ខ្ញុំប្រើកម្មវិធីស្រាវជ្រាវក្រុមគ្រួសារ ។ ខ្ញុំបង្រៀនគាត់ពីរបៀបបន្ថែមកម្រងអនុស្សាវរីយ៍ ។ ខ្ញុំក៏បានជួយគាត់បន្ថែមមនុស្សដែលបាត់ ទៅក្នុងមែកធាងគ្រួសាររបស់គាត់ផងដែរ ។ សាច់ញាតិរបស់គាត់មួយចំនួនមានឈ្មោះច្រើនណាស់ ! វាត្រូវចំណាយពេលយូរដើម្បីដាក់ឈ្មោះទាំងអស់នោះចូល ។ ប៉ុន្តែ ខ្ញុំពិតជារីករាយណាស់ ដែលខ្ញុំអាចជួយគាត់រៀនប្រើកម្មវិធីស្រាវជ្រាវក្រុមគ្រួសារ ដូចប៉ាខ្ញុំបានជួយខ្ញុំដែរ ។

**តើគម្រោងពង្សប្រវត្តិអ្វីដែលប្អូនចង់ធ្វើបន្ទាប់ ?**

ខ្ញុំចង់ធ្វើវីដេអូសម្រាប់គ្រួសារ និងមិត្តភក្តិរបស់ខ្ញុំ ដើម្បីជួយពួកគេរៀនពីរបៀបប្រើកម្មវិធីស្រាវជ្រាវក្រុមគ្រួសារ ។ ពេលខ្ញុំចាប់ផ្ដើមធ្វើ ខ្ញុំបានរៀនច្រើនណាស់ ។ ខ្ញុំចង់បង្រៀនអ្នកដទៃទៀត ដើម្បីពួកគេអាចធ្វើដូច្នេះដែរ ។

